**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៧៥ ប្រក.កសក

# ប្រកាស
## ស្តីពី
## គំរូពាក្យស្នើសុំ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវគំរូពាក្យស្នើសុំ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំគ្រប់ប្រភេទ ក្នុងការគ្រប់គ្រងពូជដំណាំគ្រប់ប្រភេទ ដែលធ្វើអាជីវកម្មគ្រប់រូបភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ៖

- កំណត់នូវនីតិវិធីសម្រាប់ការគ្រប់គ្រងការធ្វើអាជីវកម្មពូជដំណាំគ្រប់ប្រភេទ
- អនុវត្តវិធានការត្រួតពិនិត្យគុណភាពពូជដំណាំដែលធ្វើអាជីវកម្ម និងធ្វើចរាចរណ៍លើទីផ្សារ
- បញ្ជាក់គុណភាពពូជដំណាំ ចងក្រង និងធ្វើការចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិ
- ការពារផលប្រយោជន៍របស់អ្នកបង្កាត់ពូជដំណាំ អាជីវករពូជដំណាំ ព្រមទាំងកសិករដែលប្រើប្រាស់ពូជដំណាំនៅក្នុងផលិតកម្មកសិកម្ម។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះពូជដំណាំគ្រប់ប្រភេទ រួមមានប្រភេទពូជដំណាំដែលមានស្រាប់ និងពូជថ្មីនៃដំណាំ ព្រមទាំងរាល់សកម្មភាពដែលពាក់ព័ន្ធនឹងពូជដំណាំគ្រប់ប្រភេទ ក្នុងគោលបំណងឬក្រៅគោលបំណងអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែការប្រើប្រាស់ជាក់លាក់ក្នុងផលិតកម្មកសិកម្មគ្រួសារ។

## ជំពូកទី២

## ការបញ្ជាក់គុណភាពពូជដំណាំ

### ផ្នែកទី១ ៖ ការចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិ

**ប្រការ ៤.-**

ពូជដំណាំគ្រប់ប្រភេទដែលអាចអនុញ្ញាតឱ្យធ្វើអាជីវកម្មគ្រប់រូបភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានត្រូវឆ្លងកាត់ការបញ្ជាក់គុណភាពពូជដំណាំ និងត្រូវបានចុះបញ្ជីប្រភេទពូជនៅក្នុងបញ្ជីប្រភេទពូជរបស់ជាតិ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

**ប្រការ ៥.-**

ពូជដំណាំដែលអាចផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព សម្រាប់ការធ្វើអាជីវកម្មនិងធ្វើចរាចរណ៍ទីផ្សារបាន គឺជាប្រភេទពូជដែលស្ថិតនៅក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ និងមិនត្រូវស្ថិតនៅក្នុងបញ្ជីប្រភេទពូជដំណាំដែលបង្កគ្រោះថ្នាក់ឡើយ។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវចងក្រងបញ្ជីប្រភេទពូជដំណាំរបស់ជាតិដែលមានស្រាប់ និងធ្វើសម្រង់ប្រចាំឆ្នាំនូវប្រភេទពូជដែលបានផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ និងដែលបានយល់ព្រមចុះក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវកំណត់បញ្ជីប្រភេទពូជដំណាំដែលបង្កគ្រោះថ្នាក់ ដើម្បីជាទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងអាជីវកម្មពូជដំណាំ។

**ប្រការ ៦.-**

ប្រភេទពូជដំណាំដែលមានស្រាប់ អាចធ្វើការចុះបញ្ជីបាន ដោយផ្អែកលើលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

១- មានឈ្មោះសម្គាល់ជាក់លាក់ ដោយមិនភាន់ច្រឡំជាមួយប្រភេទពូជដំណាំផ្សេងទៀតដែលត្រូវបានចុះបញ្ជីរួច។

២- ត្រូវភ្ជាប់ឯកសារស្តីពី "សេចក្តីអធិប្បាយអំពីប្រភេទពូជដំណាំ" ដែលចេញដោយប្រភពដើមផលិតពូជដំណាំ ឬអ្នកបង្កាត់ពូជ ដើម្បីបញ្ជាក់ចរិតលក្ខណៈនៃប្រភេទពូជដំណាំនោះ។

៣- រក្សាទុកឈ្មោះដើមរបស់ប្រភេទពូជ ក្នុងករណីជាប្រភេទពូជដំណាំនាំចូលពីបរទេស។

៤- បានទទួលការវាយតម្លៃចរិតលក្ខណៈលើភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថិរភាព ដែលអាចធ្វើអត្តសញ្ញាណកម្មនៃប្រភេទពូជបាន។

៥- មានព័ត៌មាន និងទិន្នន័យពិសោធន៍ស្រាវជ្រាវច្បាស់លាស់លើសម្ថែងកម្មរបស់ប្រភេទពូជដំណាំ ដែលបញ្ជាក់ដោយគ្រឹះស្ថាន ឬស្ថានីយពិសោធន៍ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៦- លក្ខខណ្ឌតម្រូវផ្សេងទៀត ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ផ្នែកទី២ ៖ ការបញ្ជាក់គុណភាពពូជដំណាំ

**ប្រការ ៧.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលធ្វើអាជីវកម្មពូជដំណាំ រួមមានការផលិតនិងកែច្នៃ ការនាំចេញ និងការនាំចូលពូជដំណាំគ្រប់ប្រភេទ ក្នុងគោលបំណងធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំធ្វើការបញ្ជាក់គុណភាពពូជដំណាំ នៅអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សំណុំបែបបទសម្រាប់ការស្នើសុំវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ ៨.-**

ពូជដំណាំដែលស្នើសុំធ្វើការបញ្ជាក់គុណភាព ត្រូវឆ្លងកាត់ការវាយតម្លៃនៅទីវាលដោយសមត្ថកិច្ចជំនាញ និងការវិភាគគុណភាពដោយមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ផ្សេងទៀត ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ដំណើរការវិភាគគុណភាពពូជដំណាំ និងការវាយតម្លៃនៅទីវាល ត្រូវអនុលោមតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការសាកល្បង ការយកសំណាក ការចាត់ថ្នាក់ ការកំណត់ស្តង់ដារគុណភាពពូជដំណាំ និងនីតិវិធីនៃការត្រួតពិនិត្យលើគុណភាពពូជដំណាំ និងឧបសម្ព័ន្ធពាក់ព័ន្ធនៃប្រកាសនោះ។

**ប្រការ ៩.-**

គ្រឹះស្ថានស្រាវជ្រាវ និងស្ថានីយពិសោធន៍ពូជដំណាំសាធារណៈ ឬឯកជនដែលស្ថិតក្រោមកម្មវត្ថុធ្វើអាជីវកម្មពូជដំណាំ ឬធ្វើសេវាកម្មបច្ចេកទេសពូជដំណាំ ត្រូវមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គំរូវិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់គ្រឹះស្ថានស្រាវជ្រាវ ឬស្ថានីយពិសោធន៍ ធ្វើសេវាកម្មបច្ចេកទេសពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ១០.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើការបញ្ជាក់គុណភាពពូជដំណាំ អាចស្នើសុំលិខិតអនុញ្ញាតនាំចូលសំណាកពូជដំណាំនោះជាមុន នៅអគ្គនាយកដ្ឋានកសិកម្ម។ សំណាកពូជដំណាំអាចត្រូវបានអនុញ្ញាតឱ្យនាំចូលសម្រាប់តែធ្វើការវិភាគ និងពិសោធន៍សាកល្បងប៉ុណ្ណោះ។

**ប្រការ ១១.-**

សំណុំឯកសារពាក្យស្នើសុំការបញ្ជាក់គុណភាពពូជដំណាំ និងការចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិ រួមជាមួយលទ្ធផលនៃការពិសោធសាកល្បង ត្រូវបានពិនិត្យ និងវាយតម្លៃ ដោយអគ្គនាយកដ្ឋានកសិកម្មលើភាពគ្រប់គ្រាន់ និងភាពត្រឹមត្រូវនៃសំណុំឯកសារ។

សំណុំឯកសារពាក្យស្នើសុំការបញ្ជាក់គុណភាពពូជដំណាំ ត្រូវភ្ជាប់នូវឯកសារប្រភពដើមដែលផលិតពូជដំណាំនោះ ដោយបង្ហាញនូវព័ត៌មានបច្ចេកទេសស្តីពីពូជដំណាំ សេចក្តីអធិប្បាយអំពីប្រភេទពូជដំណាំ ដំណើរការផលិត ការចាត់ថ្នាក់ និងការវេចខ្ចប់ពូជដំណាំ ឯកសារបញ្ជាក់ពីសិទ្ធិអនុញ្ញាតធ្វើផលិតកម្មពូជដំណាំ និងការចុះបញ្ជីប្រភេទពូជដំណាំនៅប្រទេសប្រភពដើម ព្រមទាំងព័ត៌មានពាក់ព័ន្ធផ្សេងទៀតតាមការតម្រូវ ដូចមានភ្ជាប់នៅក្នុងគំរូពាក្យស្នើសុំ។

សំណុំឯកសារត្រូវបង្វែរឱ្យអ្នកស្នើសុំវិញ ក្នុងករណីមន្ត្រីទទួលសំណុំឯកសារបានពិនិត្យឃើញថា ឯកសារមិនគ្រប់គ្រាន់ឬមិនត្រឹមត្រូវ ស្របតាមការតម្រូវដូចបានកំណត់នៅក្នុងពាក្យស្នើសុំ។

**ប្រការ ១២.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើការបញ្ជាក់គុណភាពពូជដំណាំ អាចទទួលព័ត៌មានស្តីពីលទ្ធផលនៃដំណើរការពិនិត្យសម្រេចលើសំណុំឯកសារពាក្យស្នើសុំរបស់ខ្លួន នៅអគ្គនាយកដ្ឋានកសិកម្ម នៅក្នុងរយៈពេលមិនលើសពី ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលយកសំណុំឯកសារពាក្យស្នើសុំគ្រប់គ្រាន់ និងសំណាកពូជដំណាំសម្រាប់ពិសោធន៍សាកល្បង។

រយៈពេលនៃការពិសោធសាកល្បងសម្តែងកម្មប្រភេទពូជ និងសម្រាប់ការវាយតម្លៃភាពខុសប្លែក ឯក-សណ្ឋានភាព និងស្ថិរភាពរបស់ប្រភេទពូជដំណាំ ដើម្បីចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិ មិនត្រូវបានរាប់បញ្ចូលជាមួយរយៈពេលនៃដំណើរការពិនិត្យសម្រេចលើសំណុំឯកសារពាក្យស្នើសុំ និងការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំឡើយ។

**ប្រការ ១៣.-**

អគ្គនាយកដ្ឋានកសិកម្ម ចេញវិញ្ញាបនបត្របញ្ជាក់គុណភាពគ្រាប់ពូជដំណាំ រួមជាមួយការចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិ ក្នុងករណីសំណុំឯកសារពាក្យស្នើសុំនិងលទ្ធផលពិសោធន៍សាកល្បងបានបំពេញលក្ខខណ្ឌ និងភាពអនុលោម ស្របតាមស្តង់ដារគុណភាពពូជដំណាំដែលស្នើសុំ។

ក្នុងករណីសំណុំឯកសារពាក្យស្នើសុំ និងលទ្ធផលពិសោធន៍សាកល្បង មិនទាន់បំពេញបាននូវលក្ខខណ្ឌអនុលោមភាពស្របតាមស្តង់ដារគុណភាពពូជដំណាំដែលស្នើសុំនោះ អគ្គនាយកដ្ឋានកសិកម្មអាចបដិសេធសំណើសុំឬតម្រូវឱ្យមានការបំពេញ និងកែតម្រូវតាមស្តង់ដារកំណត់ជាចាំបាច់។

**ប្រការ ១៤.-**

អគ្គនាយកដ្ឋានកសិកម្ម អាចបដិសេធសំណើសុំការបញ្ជាក់គុណភាពពូជដំណាំ ក្នុងករណីដូចខាងក្រោម៖

១- ពូជដំណាំដែលស្នើសុំ មិនទាន់បានចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិ។

២-ឯកសារពាក្យស្នើសុំ មិនច្បាស់លាស់ មិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់តាមការតម្រូវ។

៣-លទ្ធផលនៃដំណើរការត្រួតពិនិត្យគុណភាពពូជដំណាំ មិនឆ្លើយតបតាមការតម្រូវលក្ខខណ្ឌនិងភាពអនុលោម ស្របតាមស្តង់ដារគុណភាពពូជដំណាំនោះ។

៤- ព័ត៌មានបច្ចេកទេសស្ដីពីពូជដំណាំមិនពិត ក្លែងព័ត៌មាន និងទិន្នន័យបច្ចេកទេស ឬចម្លងព័ត៌មានពីប្រភពផ្សេង។

៥- ពូជដំណាំដែលស្នើសុំ ស្ថិតនៅក្នុងបញ្ជីប្រភេទពូជដំណាំបង្កគ្រោះថ្នាក់ឬជាប្រភេទពូជដំណាំដែលត្រូវបានហាមឃាត់ដោយបទដ្ឋានគតិយុត្តជាតិ អន្តរជាតិ ឬតំបន់ នៅក្នុងការធ្វើអាជីវកម្ម និងការប្រើប្រាស់។

៦- ពូជដំណាំដែលអាចមានហានិភ័យចំពោះសុវត្ថិភាពស្បៀងអាហារ សុខភាពសាធារណៈ និងបរិស្ថាន។

**ប្រការ ១៥.-**

វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ត្រូវបានកំណត់សុពលភាពដោយផ្អែកតាមប្រភេទពូជដំណាំ និងស្តង់ដារពូជដំណាំនីមួយៗ។

វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ អាចស្នើសុំបន្តសុពលភាពបាន ក្នុងករណីពូជដំណាំនោះ ត្រូវបានត្រួតពិនិត្យគុណភាពឡើងវិញ និងរក្សាបាននូវគុណភាពដើមស្របតាមស្តង់ដារគុណភាពពូជដំណាំនោះ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំនាំចូលពូជដំណាំសម្រាប់ធ្វើពាណិជ្ជកម្ម អាចត្រូវបានអនុញ្ញាតក្នុងបរិមាណសមស្របសម្រាប់តែរយៈពេលសុពលភាព ដែលបានកំណត់ក្នុងវិញ្ញាបនបត្របញ្ជាក់គុណភាពប៉ុណ្ណោះ។

## ជំពូកទី៣
## អាជីវកម្មពូជដំណាំ

**ប្រការ ១៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើអាជីវកម្មពូជដំណាំ រួមមានការផលិត ការកែច្នៃ ការបណ្តុះកូនដំណាំ និងការធ្វើចរាចរណ៍លើទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រូបវន្តបុគ្គលឬនីតិបុគ្គល អាចស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះបាន ក្នុងករណីពូជដំណាំនោះ ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យ និងការវាយតម្លៃគុណភាពជាមុន និងបានទទួលវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ និងការចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិរួច ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងប្រកាសនេះ។

សំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ ១៧.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ នៅអគ្គនាយកដ្ឋានកសិកម្ម ដោយត្រូវបំពេញលក្ខខណ្ឌតម្រូវ និងឯកសារភ្ជាប់ដូចបានកំណត់នៅក្នុងគំរូពាក្យស្នើសុំ ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ អាចទទួលលទ្ធផលនៃការសម្រេចរបស់អគ្គនាយកដ្ឋានកសិកម្ម លើពាក្យស្នើសុំរបស់ខ្លួនក្នុងរយៈពេលមិនលើសពី ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំពេញលេញ។

លិខិតអនុញ្ញាតធ្វើអាជីវកម្មផលិតពូជដំណាំ មានសុពលភាពរយៈពេល៣(បី)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូត ដោយអគ្គនាយកដ្ឋានកសិកម្ម នៅមុនកាលបរិច្ឆេទផុតសុពលភាព។

**ប្រការ ១៨.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើចរាចរណ៍ពូជដំណាំលើទីផ្សារ និងការបណ្ដុះកូនដំណាំសម្រាប់ចរាចរណ៍ទីផ្សារ នៅក្នុងរង្វង់ដែនដីរាជធានី ខេត្ត នីមួយៗនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតចរាចរណ៍ទីផ្សារពូជដំណាំដែលចេញដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សាមី។

**ប្រការ ១៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតចរាចរណ៍ទីផ្សារពូជដំណាំ អាចទទួលលទ្ធផលនៃការសម្រេចរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី ក្នុងរយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំគ្រប់គ្រាន់ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លិខិតអនុញ្ញាតចរាចរណ៍ពូជដំណាំលើទីផ្សារ មានសុពលភាពរយៈពេល ៣(បី)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរ ឬការដកហូត ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

នៅក្នុងរយៈពេល១(មួយ)ខែ មុនកាលបរិច្ឆេទផុតសុពលភាព រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ។ ករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

## ជំពូកទី៤
## ការនាំចូល ការនាំចេញ និងការដឹកជញ្ជូនពូជដំណាំ

**ប្រការ ២០.-**

ការនាំចូល នាំចេញពូជដំណាំ អាចប្រព្រឹត្តទៅបាន លុះត្រាតែរូបវន្តបុគ្គលឬនីតិបុគ្គលបានកាន់កាប់នូវវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំដែលបានចុះក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិរួច មានលិខិតអនុញ្ញាតធ្វើអាជីវកម្ម និងត្រូវមានលិខិតអនុញ្ញាតនាំចូល នាំចេញពូជដំណាំនោះ។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលធ្វើប្រតិបត្តិការនាំចូល នាំចេញពូជដំណាំគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំនៅអគ្គនាយកដ្ឋានកសិកម្ម ដោយត្រូវបំពេញសំណុំឯកសារពាក្យស្នើសុំឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់។

សំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតនាំចូល នាំចេញពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

**ប្រការ ២១.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំនាំចូលពូជដំណាំសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងអាជីវកម្ម ការប្រើប្រាស់ជាក់លាក់ និងសម្រាប់ការពិសោធសាកល្បង មិនតម្រូវជាមុនឱ្យភ្ជាប់នូវវិញ្ញាបនបត្របញ្ជាក់គុណភាព និងលិខិតអនុញ្ញាតធ្វើអាជីវកម្មឡើយ ប៉ុន្តែត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- បញ្ជាក់អំពីទីកន្លែង គោលបំណងប្រើប្រាស់ និងហេតុផលនៃការប្រើប្រាស់ពូជដំណាំដែលស្នើសុំ។
២- បញ្ជាក់អំពីបរិមាណពូជដំណាំ ដែលត្រូវស្នើសុំនាំចូលស្របតាមគោលបំណងប្រើប្រាស់។
៣- នៅលើសំបកវេចខ្ចប់ ត្រូវមានស្លាកព័ត៌មានបង្ហាញពាក្យសញ្ញាថា "សម្រាប់គោលបំណងប្រើប្រាស់ជាក់លាក់" ឬ "សម្រាប់ក្រៅគោលបំណងអាជីវកម្ម" ។
៤- ឯកសារយថាភូតបញ្ជាក់នូវអត្តសញ្ញាណនៃអ្នកស្នើសុំ ដែលមានភាពសមស្របតាមគោលបំណងប្រើប្រាស់ និងធានាភាពស្របច្បាប់។
៥- ឯកសារប្រភពដើមរបស់ពូជដំណាំ ដែលផ្ដល់ព័ត៌មានបច្ចេកទេសអំពីពូជដំណាំ ព្រមទាំងព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធពូជដំណាំនោះ។
៦- ឯកសារផ្សេងទៀតតាមការចាំបាច់ ក្នុងក្របខណ្ឌនៃការគ្រប់គ្រងពូជដំណាំ។

**ប្រការ ២២.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំនាំចូលពូជដំណាំ សម្រាប់ផលិតកម្ម និងពាណិជ្ជកម្មពូជដំណាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ភ្ជាប់ឯកសារប្រភពដើម ដែលបង្ហាញពីព័ត៌មានអំពីចំណាត់ថ្នាក់គ្រាប់ពូជដំណាំនោះ។

២- បញ្ជាក់អំពីបរិមាណពូជដំណាំ ដែលត្រូវស្នើសុំនាំចូលស្របតាមគោលបំណងប្រើប្រាស់។

៣- នៅលើសំបកវេចខ្ចប់ ត្រូវមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ។

៤- ពូជដំណាំដើមដែលស្នើសុំ ត្រូវតែជាប្រភេទពូជដែលមាននៅក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ និងត្រូវឆ្លងកាត់ដំណើរការត្រួតពិនិត្យ និងការបញ្ជាក់គុណភាពស្របតាមនីតិវិធី។

៥- ពូជដំណាំដែលបានពីផលិតកម្មនៃប្រភេទពូជដើមដែលស្នើសុំ ត្រូវបានត្រួតពិនិត្យគុណភាព និងកំណត់ចំណាត់ថ្នាក់ស្របតាមស្តង់ដារគុណភាពពូជដំណាំ។

៦- ឯកសារផ្សេងទៀតតាមការចាំបាច់ ក្នុងក្របខណ្ឌនៃការគ្រប់គ្រងពូជដំណាំ។

**ប្រការ ២៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតនាំចូល នាំចេញពូជដំណាំ អាចទទួលលទ្ធផលនៃការសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួន ក្នុងរយៈពេលមិនលើសពី២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលសំណុំឯកសារពាក្យស្នើសុំពេញលេញ នៅអគ្គនាយកដ្ឋានកសិកម្ម។

លិខិតអនុញ្ញាតនាំចូល នាំចេញពូជដំណាំ ត្រូវចេញដោយអគ្គនាយកដ្ឋានកសិកម្មជូនអ្នកស្នើសុំដោយផ្អែកតាមសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ២៤.-**

លិខិតអនុញ្ញាតនាំចូល នាំចេញពូជដំណាំ មានសុពលភាពរយៈពេល១(មួយ)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរ ឬការដកហូត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

**ប្រការ ២៥.-**

បន្ថែមលើលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងការនាំចូលទំនិញរូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការនាំចូលពូជដំណាំ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ធ្វើប្រតិវេទន៍ជាមុនមកអគ្គនាយកដ្ឋានកសិកម្ម ក្នុងរយៈពេលយ៉ាងតិច១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ នៅមុនពេលដែលពូជដំណាំនោះ បាននាំមកដល់ច្រកទ្វារនាំចូលនៃព្រំដែនព្រះរាជាណាចក្រកម្ពុជា។

២- ត្រូវមានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ចេញដោយសមត្ថកិច្ចនៃប្រទេសនាំចេញ។

៣- ត្រូវមានលិខិតអនុញ្ញាតនាំចូលដែលចេញដោយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤- ត្រូវបំពេញលក្ខខណ្ឌភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៦.-**

បន្ថែមលើលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងការនាំចេញទំនិញ រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការនាំចេញពូជដំណាំ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ធ្វើប្រតិវេទន៍ជាមុនមកអគ្គនាយកដ្ឋានកសិកម្ម ក្នុងរយៈពេលយ៉ាងតិច១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការនៅមុនពេលដែលពូជដំណាំនោះ បាននាំទៅដល់ច្រកទ្វារនាំចេញនៃព្រំដែនព្រះរាជាណាចក្រកម្ពុជា។

២- ត្រូវជូនដំណឹងមកភ្នាក់ងារភូតគាមអនាម័យដែលនៅជិតបំផុត ក្នុងរយៈពេលយ៉ាងតិច១ (មួយ)ថ្ងៃ មុនពេលពូជដំណាំនោះបាននាំទៅដល់ច្រកទ្វារនាំចេញនៃព្រះរាជាណាចក្រកម្ពុជា។

៣- ត្រូវមានលិខិតអនុញ្ញាតនាំចេញ ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤- ត្រូវមានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ចេញដោយអគ្គនាយកដ្ឋានកសិកម្ម។

៥- ត្រូវបំពេញលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល។

**ប្រការ ២៧.-**

ក្នុងគោលបំណងរក្សាគុណភាពពូជដំណាំ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដឹកជញ្ជូនពូជដំណាំ ក្នុងគោលបំណងនាំចូល នាំចេញឬនាំឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ត្រូវធានាគុណភាព និងសុវត្ថិភាពនៃសំបករវេចខ្ចប់ មធ្យោបាយផ្ទុក និងអនាម័យនៃមធ្យោបាយដឹកជញ្ជូនពូជដំណាំ។

២- ការពារការចម្លងសមាសភាពចង្រៃភូតគាមអនាម័យ និងបណ្តាសមាសភាពចង្រៃបង្កគ្រោះថ្នាក់ផ្សេងទៀត ដែលអាចឆ្លងរាលដាលនៅតាមផ្លូវដឹកជញ្ជូន។

៣- ក្នុងករណីមានរបើកស្លាកសុវត្ថិភាព រហែកសំបកវេចខ្ចប់ ឬធ្លុះធ្លាយមធ្យោបាយផ្ទុកពូជដំណាំ ម្ចាស់ពូជដំណាំ ត្រូវរាយការណ៍ជាបន្ទាន់មកភ្នាក់ងារអធិការកិច្ចពូជដំណាំឬភ្នាក់ងារភូតគាមអនាម័យ និងសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុតដើម្បីចាត់វិធានការ។

## ជំពូកទី៥
## វិធានរួមសម្រាប់អាជីវកម្មពូជដំណាំ

**ប្រការ ២៨.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ លិខិតអនុញ្ញាតធ្វើប្រតិបត្តិការនាំចូល នាំចេញពូជដំណាំ និងលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំគ្រប់ប្រភេទ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ត្រូវបំពេញសំណុំបែបបទស្នើសុំឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ ស្របតាមការតម្រូវនៅក្នុងពាក្យស្នើសុំ។

២- ត្រូវមានសមត្ថភាពក្នុងការធ្វើប្រតិបត្តិការដែលពាក់ព័ន្ធនឹងការស្នើសុំរបស់ខ្លួន ដោយត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រតិបត្តិការអាជីវកម្មរបស់ខ្លួនជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តសាមី និងអគ្គនាយកដ្ឋានកសិកម្ម។ របាយការណ៍ត្រូវភ្ជាប់ជាមួយនូវពាក្យស្នើសុំធ្វើប្រតិបត្តិការអាជីវកម្មពូជដំណាំនៅគ្រាបន្ទាប់ដែលត្រូវពិនិត្យ និងវាយតម្លៃសម្រាប់ការផ្តល់លិខិតអនុញ្ញាតឬវិញ្ញាបនបត្រពាក់ព័ន្ធដែលត្រូវស្នើសុំ។

៣- ត្រូវមានការយល់ដឹង និងអនុវត្តបានត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់ និងបច្ចេកទេស នៅក្នុងប្រតិបត្តិការអាជីវកម្មពូជដំណាំ និងមិនធ្លាប់ទទួលទណ្ឌកម្មឬការពិន័យណាមួយពាក់ព័ន្ធនឹងការធ្វើអាជីវកម្មពូជដំណាំនៅក្នុងរយៈពេល២(ពីរ)ឆ្នាំចុងក្រោយ នៅមុនពេលស្នើសុំលិខិតអនុញ្ញាតឬវិញ្ញាបនបត្រថ្មី។

**ប្រការ ២៩.-**

ប្រតិបត្តិករដែលកាន់កាប់លិខិតអនុញ្ញាតធ្វើអាជីវកម្មផលិតពូជដំណាំ និងលិខិតអនុញ្ញាតនាំចេញ នាំចូលពូជដំណាំគ្រប់ប្រភេទ ត្រូវដាក់តាំងបង្ហាញនៅក្នុងគ្រឹះស្ថានរបស់ខ្លួននូវលិខិតអនុញ្ញាតទាំងនោះ និងតម្កល់ទុកនូវឯកសារវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត សម្រាប់ការត្រួតពិនិត្យដោយភ្នាក់ងារអធិការកិច្ចពូជដំណាំ។

ប្រតិបត្តិករដែលធ្វើចរាចរណ៍ពូជដំណាំ ធ្វើសន្និធិសម្រាប់លក់ តាំងលក់ពូជដំណាំគ្រប់ប្រភេទ ឬធ្វើការបណ្ដុះកូនដំណាំសម្រាប់ចរាចរណ៍ពូជដំណាំ ត្រូវតាំងបង្ហាញក្នុងគ្រឹះស្ថានរបស់ខ្លួននូវលិខិតអនុញ្ញាតចរាចរណ៍ពូជដំណាំ និងត្រូវតម្កល់ឯកសារពាក់ព័ន្ធផ្សេងទៀត ដែលបញ្ជាក់នូវប្រភពស្របច្បាប់របស់ពូជដំណាំ ការត្រួតពិនិត្យដោយភ្នាក់ងារអធិការកិច្ចពូជដំណាំ។

**ប្រការ ៣០.-**

ប្រតិបត្តិករអាជីវកម្មពូជដំណាំទាំងអស់ ត្រូវមានសៀវភៅកំណត់ត្រាពូជដំណាំ ស្របតាមគំរូសៀវភៅដែលកំណត់ដោយអគ្គនាយកដ្ឋានកសិកម្ម និងត្រូវចុះក្នុងសៀវភៅនេះជាប្រចាំនូវឈ្មោះប្រភេទពូជដំណាំ ប្រភពដើមពូជដំណាំ បរិមាណពូជដំណាំដែលនាំចូល នាំចេញ ផលិត និងសន្និធិ ព្រមទាំងព័ត៌មានចាំបាច់ផ្សេងទៀតពាក់ព័ន្ធនឹងពូជដំណាំដែលធ្វើប្រតិបត្តិការក្នុងអាជីវកម្មរបស់ខ្លួន។

ប្រតិបត្តិករដែលធ្វើអាជីវកម្មពូជដំណាំនៅដើមខ្សែ រួមមានការផលិត ការនាំចេញ និងការនាំចូលពូជដំណាំគ្រប់ប្រភេទ ត្រូវធានាប្រភពស្របច្បាប់នៃពូជដំណាំ និងត្រូវទទួលខុសត្រូវរួមគ្នាជាមួយប្រតិបត្តិករដែលធ្វើចរាចរណ៍ពូជដំណាំ លើការផ្គត់ផ្គង់ពូជដំណាំសម្រាប់ការលក់ និងចែកចាយដល់កសិករ ឬអ្នកប្រើប្រាស់ចុងក្រោយ នៅតាមរាជធានី ខេត្ត។

**ប្រការ ៣១.-**

ការផ្សាយពាណិជ្ជកម្មពូជដំណាំ អាចប្រព្រឹត្តទៅបានសម្រាប់រាល់ប្រភេទពូជដំណាំដែលបានទទួលការអនុញ្ញាតធ្វើអាជីវកម្ម មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ និងចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិ ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងប្រកាសនេះ។

អត្ថបទផ្សព្វផ្សាយ ឯកសារបោះពុម្ព រូបភាពសោតទស្សន៍ បទបង្ហាញ និងមេរៀនបច្ចេកទេសសម្រាប់សិក្ខាសាលា ឯកសារបច្ចេកទេសសម្រាប់ពិសោធន៍ ឬធ្វើបង្ហាញ និងឯកសារផ្សេងទៀតសម្រាប់ការផ្សាយប្រភេទពូជ និងពូជដំណាំគ្រប់ប្រភេទ ត្រូវមានការយល់ព្រមជាមុនពីអគ្គនាយកដ្ឋានកសិកម្ម។

**ប្រការ ៣២.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ត្រូវដាក់ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយឬការផ្សាយពាណិជ្ជកម្មប្រភេទពូជ និងពូជដំណាំនៅអគ្គនាយកដ្ឋានកសិកម្ម នៅក្នុងរយៈពេលយ៉ាងតិច៤៥(សែសិបប្រាំ)ថ្ងៃ នៅមុនកាលបរិច្ឆេទយល់ព្រមលើសំណើសុំធ្វើការផ្សព្វផ្សាយ។

ពាក្យស្នើសុំត្រូវភ្ជាប់ជាមួយនូវកម្មវិធីផ្សព្វផ្សាយប្រចាំឆ្នាំ ដែលបញ្ជាក់នូវប្រតិទិន និងទីកន្លែងដែលត្រូវអនុវត្តការផ្សព្វផ្សាយរួមជាមួយអត្ថបទ រូបភាព ឬឯកសារបច្ចេកទេស ដែលត្រូវប្រើប្រាស់ក្នុងការផ្សព្វផ្សាយ សម្រាប់ការពិនិត្យ ឬការកែតម្រូវតាមការចាំបាច់ ដោយអគ្គនាយកដ្ឋានកសិកម្ម។

បន្ទាប់ពីទទួលបានសេចក្ដីយល់ព្រមរបស់អគ្គនាយកដ្ឋានកសិកម្ម រូបវន្តបុគ្គលឬនីតិបុគ្គលមានសិទ្ធិធ្វើការផ្សព្វផ្សាយស្របតាមកម្មវិធីដែលស្នើសុំ ដោយត្រូវជូនព័ត៌មានដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ដើម្បីសហការអនុវត្ត។

**ប្រការ ៣៣.-**

ប្រតិបត្តិករពូជដំណាំត្រូវបំពេញលក្ខខណ្ឌជាមុន សម្រាប់ការស្នើសុំលិខិតអនុញ្ញាតពាក់ព័ន្ធ ដូចខាងក្រោម៖

១- សម្រាប់ការស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ និងលិខិតអនុញ្ញាតនាំចេញ នាំចូលពូជដំណាំគ្រប់ប្រភេទ ប្រតិបត្តិករត្រូវឆ្លងកាត់វគ្គបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រងពូជដំណាំ ដែលរៀបចំ និងផ្ដល់សេវាកម្មដោយអគ្គនាយកដ្ឋានកសិកម្ម។

២-សម្រាប់ការស្នើសុំលិខិតអនុញ្ញាតធ្វើចរាចរណ៍ពូជដំណាំ នៅតាមរាជធានី ខេត្ត ប្រតិបត្តិករត្រូវឆ្លងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងពូជដំណាំដែលត្រូវរៀបចំ និងផ្តល់សេវាកម្មដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ដោយសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម។

គោលការណ៍ណែនាំ និងកម្មវិធីសម្រាប់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងពូជដំណាំ ត្រូវកំណត់ដោយអគ្គនាយកដ្ឋានកសិកម្ម។

**ប្រការ ៣៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការពាក់ព័ន្ធអាជីវកម្មពូជដំណាំ ត្រូវទទួលបន្ទុកបង់កម្រៃសេវាសាធារណៈតាមប្រភេទប្រតិបត្តិការនីមួយៗ ដែលត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចខាងក្រោម៖

១-ការស្នើសុំធ្វើវិភាគគុណភាពពូជដំណាំ និងពិសោធន៍សាកល្បងប្រភេទពូជដំណាំ។

២-ការវាយតម្លៃភាពឧសប្លែក ឯកសណ្ឋានភាព និងស្ថិរភាពពូជថ្មីនៃដំណាំ។

៣-ការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំនិងការចុះបញ្ជីប្រភេទពូជដំណាំរបស់ជាតិ។

៤-ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ និងលិខិតអនុញ្ញាតនាំចូល នាំចេញពូជដំណាំ។

៥-ការចេញលិខិតអនុញ្ញាតចរាចរណ៍ពូជដំណាំ។

៦-ការឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងពូជដំណាំ។

៧-ការចេញវិញ្ញាបនបត្រទទួលស្គាល់គ្រឹះស្ថានស្រាវជ្រាវ ឬមន្ទីរពិសោធន៍ ដែលធ្វើសេវាកម្មបច្ចេកទេសពូជដំណាំ។

**ប្រការ ៣៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលផ្ទេរសិទ្ធិលើលិខិតអនុញ្ញាតពាក់ព័ន្ធការធ្វើអាជីវកម្មពូជដំណាំ ត្រូវស្នើសុំការយល់ព្រមជាមុន ពីអគ្គនាយកដ្ឋានកសិកម្មឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ដែលចេញលិខិតអនុញ្ញាតនោះ។

សិទ្ធិវន្តបុគ្គលដែលបានទទួលសិទ្ធិពីអ្នកកាន់កាប់លិខិតអនុញ្ញាតដើម ត្រូវទទួលខុសត្រូវលើការបំពេញកាតព្វកិច្ចពាក់ព័ន្ធ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ រួមទាំងប្រកាសនេះ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**ប្រការ ៣៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការអាជីវកម្មពូជដំណាំគ្រប់ប្រភេទ ត្រូវទទួលខុសត្រូវចំពោះពូជដំណាំរបស់ខ្លួនដែលដាក់តាំងលក់ឬធ្វើសន្និធិសម្រាប់លក់នៅក្នុងគ្រឹះស្ថានឬឃ្លាំងសន្និធិរបស់ខ្លួនឬធ្វើចរាចរណ៍លើទីផ្សារ ដោយត្រូវគោរពនិងអនុវត្តតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំរួមទាំងប្រកាសនេះ និងត្រូវសហការបង្កលក្ខណៈងាយស្រួលដល់គ្រប់សកម្មភាពបណ្តុះបណ្តាលណែនាំ ត្រួតពិនិត្យ និងអនុវត្តច្បាប់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ និងមន្ត្រីសបត្តកិច្ចជំនាញ។

**ប្រការ ៣៧.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដែលមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នក

បង្កាត់ពូជដំណាំ។ ពូជដំណាំល្មើស ត្រូវឃាត់ទុកដោយភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធី។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ ៣៨.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣៩.–**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី...០៦....ខែ...កក្កដា...ឆ្នាំ២០១៧.

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- -ក្រសួងពាណិជ្ជកម្ម
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -សាលារាជធានី ខេត្ត
- -ដូចប្រការ ៣៩
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ